ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកា
## តាមនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១៧៣

ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១

សាលដីកា

លេខ ២០១I

ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម | [redacted] | ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| ២-ឯកឧត្តម | [redacted] | ចៅក្រម |
| ៣-ឯកឧត្តម | [redacted] | ចៅក្រម |
| ៤-ឯកឧត្តម | [redacted] | ចៅក្រម |
| ៥-ឯកឧត្តម | [redacted] | ចៅក្រម |

ក្រឡាបញ្ជីសវនាការ

លោក [redacted]

តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ១២០ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ របស់តំណាងមហាអយ្យការអមតុលាការកំពូល ចំពោះសាលដីកាលេខ ១៧ "ក្រ.II.សវ" ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ដែលមាន៖

**-ជនជាប់ចោទ ៖**

១.ឈ្មោះ [redacted] មាស ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។ (ក្នុងឃុំ)

២.ឈ្មោះ [redacted] ក្តាម ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន នៅភូមិ[redacted](រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។ (ក្នុងឃុំ)





Scanned with CamScanner

៣.ឈ្មោះ [redacted] ផុនា ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន នៅភូមិ[redacted] (រ) ម្ដាយឈ្មោះ [redacted]) នៅលើវ ទោសពីមុនគ្មាន។ (ក្នុងឃុំ)

៤.ឈ្មោះ [redacted] ចិន ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលើវ ទោសពីមុនគ្មាន។ (ក្នុងឃុំ)

៥.ឈ្មោះ [redacted] ប៊ី ហៅ ផ្អែក ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលើវ ទោសពីមុនគ្មាន។ (ក្នុងឃុំ)

៦.ឈ្មោះ [redacted] សាឯម ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិអំពុក [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលើវ ទោសពីមុនគ្មាន។ (ក្នុងឃុំ)

-មេធាវីការពារសិទ្ធិ៖ លោក [redacted] បូរ៉ា និងលោក [redacted] ឃុំ

**<u>ជាប់ចោទពីបទ</u> ៖ ឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

**ដើមបណ្ដឹងរដ្ឋប្បវេណី៖**

១.ឈ្មោះ [redacted] ភុន ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន នៅភូមិត្រពាំង ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។

២.ឈ្មោះ [redacted] រ៉ាក់ ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន នៅភូមិត្រពាំង ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។

៣.ឈ្មោះ [redacted] ស៊ីប៉ាង ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន នៅភូមិខ្នារ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។

៤.ឈ្មោះ [redacted] ហ្សួន ហៅ ពិត ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន នៅភូមិត្រពាំង ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។

-មេធាវីការពារសិទ្ធិ៖ លោក [redacted] សុនៅ

តំណាងមហាអយ្យការអមតុលាការកំពូល ជាអ្នកប្ដឹងសាទុក្ខ

**- អំពីអង្គហេតុ**

កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១២ នៅចំណុចបរិវេណផ្ទះលក់ស៊ុប និងគ្រឿងក្លែម យីហោ៨៨ ខាងកើតផ្លូវបំបែក ក្នុងភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម មានក្រុមក្មេង ២ក្រុមផ្សេងគ្នា បានអង្គុយស៊ីផឹកក្បែរគ្នា។ ក្នុងពេលផឹកស៊ីនោះ ក្រុមទាំងពីរបានខឹងងាក់គ្នាទៅវិញទៅមករឿងស្រីបម្រើ ដោយលំអៀង ជាហេតុធ្វើឱ្យភាគីម្ខាងមានការខឹងសម្បាមានគំនុំក្នុងចិត្ត។ ក្រោយពេលស៊ីផឹកចប់ ភាគីក្មេងមួយក្រុមមានគ្នា៦នាក់ ដែលមាន



Scanned with CamScanner

ឈ្មោះ [redacted] ផុនា ឈ្មោះ [redacted] មាស ឈ្មោះ [redacted] ក្តាម និងបីនាក់ទៀតមិនស្គាល់ឈ្មោះ បានជិះម៉ូតូ២គ្រឿង ម៉ាកហុងដាសេ១២៥ និងម៉ាកអ៊ែរប្លែង ចេញទៅមុនៗ។ លុះវេលាម៉ោង២១ និង០០នាទី ថ្ងៃដដែលក្រុមដែលជាគូបដិបក្ស ៣នាក់ មានឈ្មោះ [redacted] រ៉ាក់ ភេទប្រុស អាយុ២៣ឆ្នាំ ឈ្មោះ [redacted] លឹមហួន ភេទប្រុស អាយុ២៦ឆ្នាំ និងឈ្មោះ [redacted] បីហ៊ាង ភេទប្រុស អាយុ២៤ឆ្នាំ បានចេញពីកន្លែងផឹកស៊ីនោះ ត្រឡប់មកផ្ទះវិញដោយជិះម៉ូតូ ២គ្រឿង តាមបណ្តោយផ្លូវជាតិលេខ៧។ លុះពេលជិះមកដល់ចំណុចបង្គោលភ្លើងលេខ ៣១៩ ភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ស្រាប់តែក្រុមរបស់ឈ្មោះ [redacted] ផុនា ឈ្មោះ [redacted] ក្តាម ឈ្មោះ [redacted] មាស និងបក្សពួកបីនាក់ទៀតបានស្ទាក់វាយតាមផ្លូវ បណ្តាលឱ្យឈ្មោះ [redacted] ឌឹរ៉ាក់ ស្លាប់ភ្លាមៗ នៅកន្លែងឯឈ្មោះ [redacted] លឹមហួន និងឈ្មោះ [redacted] បីហ៊ាង រងរបួស។ ក្រោយពេលវាយទៅលើជនរងគ្រោះបណ្តាលឱ្យស្លាប់ និងរបួសរួចហើយ ក្រុមជនល្មើសឈ្មោះ [redacted] ផុនា ឈ្មោះ [redacted] មាស និងឈ្មោះ [redacted] ក្តាម ព្រមទាំងបក្សពួក បាននាំគ្នាគេចខ្លួនអស់។ សមត្ថកិច្ចបានធ្វើការចុះពិនិត្យដល់កន្លែងកើតហេតុ និងបានកសាងសំណុំរឿងបញ្ជូនមកកាន់សាលាដំបូងខេត្តកំពង់ចាមតាមច្បាប់។

-បានឃើញ តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទ៖

១.ឈ្មោះ [redacted] មាស ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ

២.ឈ្មោះ [redacted] ក្តាម ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ

៣.ឈ្មោះ [redacted] ផុនា ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ

ទៅតុលាការដើម្បីជំនុំជម្រះ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៧២ "ខ" ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ក.កែប្រែចោទប្រកាន់លើជនជាប់ចោទឈ្មោះ៖

-[redacted] មាស ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

-[redacted] ផុនា ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

[redacted] បី ហៅ ភ្នែក ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ពីបទ ឃាតកម្មគិតទុកជាមុន (មាត្រា២០០ នៃក្រមព្រហ្មទណ្ឌ) មកជាបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ) អង្គហេតុកើតនៅភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១២។

១.ខ.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ៖

-[redacted] មាស ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

-[redacted] បី ហៅ ភ្នែក ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ដាក់ពន្ធនាគារក្នុងម្នាក់ៗចំនួន០២ឆ្នាំ តាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ

[redacted] ផុនា ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារចំនួន ០១ឆ្នាំ តាមមាត្រា២១៨ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស អង្គហេតុកើតនៅភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១២។

ប៉ុន្តែទោសខាងលើទាំងអស់នេះ (ជនជាប់ចោទទាំង០៣នាក់) ត្រូវព្យួរធម្មតា យោងតាមមាត្រា១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

២.បញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៖ ២៣២ ដ.ច ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ របស់ចៅក្រមស៊ើបសួរ ដែលបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ[redacted]មាស និងឈ្មោះ[redacted]ថុនា និងដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ២៥២ ដ.ច ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២ របស់ចៅក្រមស៊ើបសួរ ដែលបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ប៊ី ហៅ វ៉េក។

៣.ក.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] មាស និងឈ្មោះ [redacted] ប៊ី សងថ្លៃព្យាបាល និងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]លឹមហួន ចំនួន ២.០០០.០០០ (ពីរលាន)រៀល។ ការទាមទារលើសពីនេះបដិសេធចោល។

៣.ខ.បង្គាប់ឱ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ[redacted]ហ៊ា និងប្រពន្ធឈ្មោះ[redacted]ខេង ដែលជាឪពុកម្តាយរបស់ជនជាប់ចោទឈ្មោះ [redacted] ថុនា សងថ្លៃព្យាបាល និងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លឹមហួន និងឈ្មោះ [redacted] លីហ៊ាង ក្នុងម្នាក់ៗ ចំនួន៣.០០០.០០០ (បីលាន)រៀល។ ការទាមទារលើសពីនេះបដិសេធចោល។

៤.ក.កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ[redacted]ក្លាម ភេទប្រុស អាយុ១៨ឆ្នាំ ពីបទ ឃាតកម្មគិតទុកជាមុន (មាត្រា២០០នៃក្រមព្រហ្មទណ្ឌ) មកជាបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ) និងបទ ហិង្សាដោយចេតនា បណ្តាលឱ្យជនរងគ្រោះស្លាប់ (មាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ)។

៤.ខ.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted]ក្លាម ភេទប្រុស អាយុ១៨ឆ្នាំ ដាក់ពន្ធនាគារចំនួន ១៣ឆ្នាំ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងបទ ហិង្សាដោយចេតនា បណ្តាលឱ្យជនរងគ្រោះស្លាប់ អង្គហេតុកើតនៅភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១២ តាមមាត្រា២១៨ និងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

៤.គ.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ[redacted]ក្លាម សងថ្លៃព្យាបាល និងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីហ៊ាង ចំនួន ២០.០០០.០០០ (ម្ភៃលាន)រៀល។ ការទាមទារលើសពីនេះ បដិសេធចោល។

៥.ក.កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ៖

-[redacted]ចិន ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

-[redacted]សាឯម ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ពីបទ ឃាតកម្មគិតទុកជាមុន (មាត្រា២០០ នៃក្រមព្រហ្មទណ្ឌ) មកជាបទ ហិង្សាដោយចេតនាបណ្តាលឱ្យស្លាប់ជនរងគ្រោះ (មាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ)។

៥.ខ.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ៖

-[redacted]ចិន ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

[redacted]សាឯម ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ដាក់ពន្ធនាគារចំនួន១២ឆ្នាំ ពីបទ ហិង្សាដោយចេតនា បណ្តាលឱ្យជនរងគ្រោះស្លាប់ អង្គហេតុកើតនៅភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១២ តាមមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៥.គ.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ[redacted]ក្លាម ឈ្មោះ [redacted]ចិន និងឈ្មោះ [redacted] សាឯម រួមគ្នាសងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] គុន ចំនួន ៩០.០០០.០០០ (សែសិបលាន)រៀល។ ការទាមទារលើសពីនេះ បដិសេធចោល។

៦.បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ[redacted] ក្លាម ឈ្មោះ[redacted] ចិន និងឈ្មោះ[redacted]សាឯម ភ្លាម តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៧.វត្ថុចាប់យក៖

-ព្រនង់ឬស្សីទំហំ ១,៥០ ស.ម គុណ ១,២០ម៉ែត្រ ចំនួន ០១

-ខ្សែក្រវ៉ាត់ពណ៌ក្រហមទំហំ ៣,៥០ ស.ម គុណ ៩៤ ស.ម (គ្មានក្បាល) ចំនួន០១

-ខ្សែក្រវ៉ាត់ពណ៌ខ្មៅទំហំ ៣,៥០ ស.ម គុណ ១០៣ ស.ម (គ្មានក្បាល) ចំនួន០១

-ស្បែកជើងសង្រែកទំហំ ៨,៥០ ស.ម គុណ ២៧ ស.ម (ពណ៌ខ្មៅ) ចំនួន០១

-ស្បែកជើងសង្រែកទំហំ ៨,៥០ ស.ម គុណ ២៦ ស.ម (ពណ៌ខ្មៅ) ចំនួន០១

-ស្បែកជើងសង្រែកទំហំ ៨,៥០ ស.ម គុណ ២៧ ស.ម (ពណ៌ត្រាវ) ចំនួន០១

-បំណែកក្បាលខ្សែក្រវ៉ាត់ទំហំមុខកាត់ ០,៥០ ស.ម ប្រវែង ០៨ ស.ម ចំនួន០១

-បំណែកក្បាលខ្សែក្រវ៉ាត់ទំហំមុខកាត់ ០,៥០ ស.ម ប្រវែង ០៥ ស.ម ចំនួន០១

-មួកប៉ារ៉េពណ៌ស ឆ្នូតខ្មៅ ផ្លាក Adidas ចំនួន ០១

ត្រូវរឹបអូសយោងតាមមាត្រា២០៦ ចំណុច៥ មាត្រា២២៩ ចំណុច៥ មាត្រា៥៣ និងមាត្រា៥៤ នៃក្រមព្រហ្មទណ្ឌ។

៨.សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]មាស ឈ្មោះ [redacted] ក្លាម ឈ្មោះ [redacted]ធុនា ឈ្មោះ [redacted] ចិន ឈ្មោះ [redacted] ប៊ី ហៅ ភ្នែក និងឈ្មោះ [redacted]សាឯម និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] លីហ៊ាង ឈ្មោះ[redacted]លឹមហួន និងឈ្មោះ [redacted] គុន ។ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៨៥ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាឧទ្ធរណ៍ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៤ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]គុន ឈ្មោះ[redacted] លឹមហួន និងឈ្មោះ[redacted]លីហ៊ាង ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១៧ "ក្រ.II.សវ" ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលបណ្តឹងឧទ្ធរណ៍ ៨៥ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ឯកឧត្តម អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ភ្នំពេញ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២.ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៤ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]គុន ឈ្មោះ [redacted] លឹមហួន និងឈ្មោះ [redacted]លីហ៊ាង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

៣.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៧២ "ខ" ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការដដែល លើកលែងតែចំណុចទី១ ខ និងទី២ នៃសាលក្រមនេះ ត្រូវរក្សាទុកជាបានការដដែល។



Scanned with CamScanner

៤.ផ្តន្ទាទោសឈ្មោះ[redacted]មាស ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិពងទឹក [redacted](រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន និងឈ្មោះ[redacted] ប៊ី ហៅ ភ្នែក ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល០៥(ប្រាំ)ឆ្នាំ និងផ្តន្ទាទោសឈ្មោះ [redacted] ផុនា ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅ [redacted](រ) ម្តាយឈ្មោះ គោ [redacted]) នៅលីវ ទោសពីមុនគ្មាន ដាក់ពន្ធនាគារ០២ឆ្នាំ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១២។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា២១៨ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

៥.បង្គាប់មកអាជ្ញាធរមានសមត្ថកិច្ចឱ្យចាប់ឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] មាស ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និង[redacted] ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ[redacted] (រ) នៅលីវ ទោសពីមុនគ្មាន ឈ្មោះ[redacted] ប៊ី ហៅ ភ្នែក ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅ[redacted] ចាម ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ[redacted](រ) នៅលីវ ទោសពីមុនគ្មាន និងឈ្មោះ [redacted] ផុនា ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិពងទឹក ឃុំកណ្តាលជ្រុំ ស្រុកពញាក្រែក ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] ស៊ា (រ) ម្តាយឈ្មោះ[redacted]ខង (រ) នៅលីវ ទោសពីមុនគ្មាន តាមនីតិវិធីច្បាប់។

សាលដីកានេះ បានជំនុំជម្រះនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងកំបាំងមុខជនជាប់ចោទ។

បើកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

-បានឃើញ ពាក្យបណ្តឹងសាទុក្ខលេខ ១២០ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ របស់តំណាងមហាអយ្យការអមតុលាការកំពូល ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សារណាការពាររបស់តំណាងមហាអយ្យការអមតុលាការកំពូល ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១។

## នាពេលសវនាការ

-ចៅក្រមអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានថា ៖

បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ១៧ “ក្រII.សរ” ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ចោលជាអសាបង់ និងបង្វិលសំណុំរឿងនេះ ទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះឡើងវិញ។

សូមក្រុមប្រឹក្សាជំនុំជម្រះ សម្រេចតាមច្បាប់។



Scanned with CamScanner

-លោក [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] មាស ឈ្មោះ [redacted] ក្តាម ឈ្មោះ [redacted] ផុនា ឈ្មោះ [redacted] ឈ្មោះ [redacted] ចិន និងឈ្មោះ [redacted] សាឯម ធ្វើសេចក្តីសន្និដ្ឋានការពារថា៖

អង្គហេតុទាំងស្រុង បង្ហាញពីការវាយគ្នាទៅវិញទៅមក បណ្តាលឱ្យភាគីសងខាងស្លាប់ ឬរងរបួស។ គ្មានសាក្សីណាក្រៅពីជនរងគ្រោះពីររូប ([redacted] លីមហួន និង [redacted] លីហ៊ាង) ដែលបានស្គាល់តែ [redacted] ផុនា និង [redacted] មាស ជាអ្នកប្រព្រឹត្ត។ ប៉ូលិសម្នាក់ឈ្មោះ [redacted] ដែលទៅដល់កន្លែងកើតហេតុ ក្រោយកើតហេតុ (សាលក្រមទំ.៤ និង៥) និងឈ្មោះ [redacted] អុន អ្នករស់នៅមុខផ្ទះ [redacted] ក្តាម (ជនជាប់ចោទ) ដែលបានឃើញមានឈាមប្រឡាក់លើអាវជនជាប់ចោទ (ម៉ោង១១យប់) ក្រោយកើតហេតុ។ ឈាមនេះទំនងអាចជាមិនមែនឈាមរបស់អ្នកស្លាប់ ([redacted] រ៉ាក់) តែជាឈាមរបស់អ្នករងរបួសឈ្មោះ [redacted] ហ៊ាង ដែលចាក់ដោយ [redacted] ក្តាម ចំនួន ៦ ដែកពន្លាក (សាលក្រមទំ.៤)។

មិនមានភស្តុតាងបង្ហាញពីការពួនទេ។ ជនជាប់ចោទ គ្រាន់តែឈប់ម៉ូតូ និងចាប់ផ្តើមវាយគ្នានៅទីសាធារណៈនៅម៉ោងប្រហែល៨យប់ ក្រោយពីចេញកន្លែងស៊ីផឹក។ មិនមានភស្តុតាងបង្ហាញថា អ្នកប្រព្រឹត្ត មានចេតនាសម្លាប់គ្នាទេ ដោយសារក្រុមទាំងពីរ មិនមានទំនាស់វាយតប់គ្នាពីមុន។ ទំនាស់កើតដោយការគ្រាន់តែមើលមុខគ្នានៅកន្លែងស៊ីផឹក។ ជនរងគ្រោះឈ្មោះ [redacted] ហ៊ាង ក៏គិតដូចនេះដែរ (គ្មានគំនុំពីមុនទេ) ហើយក្នុងការយល់ឃើញរបស់សាលាដំបូង ក៏ដូចនេះដែរ (មានតែចេតនាហិង្សា មិនមែនចេតនាសម្លាប់) (សាលក្រមទំ.៧)។ សាលដីកាចំណុច៣ ប្រើពាក្យ "ស្ទាក់" គ្មានពាក្យ "ពួន"។ ដូចនេះបទល្មើសដែលចោទនោះ គឺហិង្សាមានចេតនាមានស្ថានទម្ងន់។ ដូចនេះ ការណ៍ដែលសាលាឧទ្ធរណ៍តម្កល់សាលក្រមនេះ គឺជាការត្រឹមត្រូវហើយ។

ឯកឧត្តមប្រធាន និងសមាជិក! មានភាពមិនច្បាស់លាស់រវាងបទល្មើសហិង្សាដោយចេតនា(មាត្រា២១៧) ឃាតកម្មគិតជាមុន (មាត្រា២០០) និងមនុស្សឃាត (មាត្រា១៩៩)។ ច្បាប់មិនច្បាស់នាំឱ្យមានការបកស្រាយខុសគ្នា ការគ្មានខ្លឹមសារបំភ្លឺ ឬណែនាំ នឹងនាំឱ្យមានការអនុវត្តខុសគ្នា មិនយុត្តិធម៌។ ក្នុងសំណុំរឿងនេះ វាបង្ហាញយ៉ាងច្បាស់អំពីបញ្ហានេះ រវាងព្រះរាជអាជ្ញា ដែលចាត់ថាជាបទមនុស្សឃាត តែចៅក្រមអះអាងថាជាបទហិង្សាដោយចេតនា។ តុលាការកំពូល ជាតុលាការចុងក្រោយ តុលាការអង្គច្បាប់ មានឥទ្ធិពល អាចបង្កើតជាយុត្តិសាស្ត្របាន។ អាស្រ័យហេតុនេះ សូមតុលាការកំពូល ពិចារណាជួយបំភ្លឺអំពីធាតុផ្សំ នៃបទល្មើសទាំងបីនេះ ដើម្បីជាផលប្រយោជន៍នៃច្បាប់។

ជនជាប់ចោទ មានចំនួន ៦រូប ដែលត្រូវបានបង្ហាញអត្តសញ្ញាណ ក្រោយពីបទល្មើស ត្រូវបានប្រព្រឹត្ត។ ក្នុងចំណោម០៦ រូប មានបីរូប ត្រូវបានចង្អុលបង្ហាញថា ជាអ្នកចូលរួមក្នុងការវាយប្រហារ ([redacted] ក្តាម, ផុនា និង [redacted] មាស)។ ដោយឡែកឈ្មោះ ចិន និង សាឯម មានភស្តុតាងតិចតួច ចង្អុលបង្ហាញពីការចូលរួម ក៏ប៉ុន្តែ ត្រូវបានចោទពីបទ ហិង្សាដោយចេតនានាំឱ្យជនរងគ្រោះស្លាប់ ទទួលទោស ១២ឆ្នាំ។ វាមិនទំនងជាយុត្តិធម៌ទេ សូមពិចារណា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យ និងពិចារណា។

-លោក [redacted] សិរីវង្ស ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] មាស ឈ្មោះ [redacted] ក្តាម ឈ្មោះ [redacted] ផុនា ឈ្មោះ [redacted] ប៊ី ឈ្មោះ [redacted] ចិន និងឈ្មោះ [redacted] សាឯម ធ្វើសេចក្តីសន្និដ្ឋានការពារថា៖

ខ្ញុំបាទ សូមឯកភាពតាមសហភាគា។

-លោក [redacted] សុនៅ ជាមេធាវីតំណាងដោយអាណិត្តអោយដើមបណ្តឹងរដ្ឋប្បវេណី ធ្វើសេចក្តីសន្និដ្ឋានការពារថា៖

ក្នុងរឿងនេះខ្ញុំបាទមិនមានសេចក្តីថ្លែងការច្រើនទេគ្រាន់តែ សូមសំណូមពរ ឯកឧត្តមមេត្តាបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ និងសូមតម្កល់សំណងទៅដដែល។



Scanned with CamScanner

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងអាណាព្យាបាលឱ្យដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១២០ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ របស់តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.យល់ឃើញថា តាមខ្លឹមសារ នៃសារណាការពារបណ្តឹងសាទុក្ខចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ របស់តំណាងមហាអយ្យការអមតុលាការកំពូល ក៏ដូចជានាពេលសវនាការផងដែរ តំណាងមហាអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំឱ្យតុលាការកំពូល បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ១៧ "ក្រII.សវ" ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ចោលជាអសារបង់ និងបង្វិលសំណុំរឿងព្រហ្មទណ្ឌនេះទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះឡើងវិញ។ ដោយសំអាងថា សេចក្តីសម្រេច នៃសាលាឧទ្ធរណ៍ភ្នំពេញ បានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងខេត្តកំពង់ចាម ដែលបានសម្រេចកែប្រែបទចោទប្រកាន់ ពីបទ ឃាតកម្មគិតទុកជាមុន តាមបញ្ញត្តិមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ មកជាបទ ហិង្សាមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ជាការមិនត្រឹមត្រូវទេ ពីព្រោះថា អំពើរបស់ជនជាប់ចោទទាំងអស់បានពួនស្ទាក់វាយជនរងគ្រោះ បណ្តាលឱ្យស្លាប់ភ្លាម គឺជាអំពើឃាតកម្មគិតទុកជាមុន ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ នោះជាការត្រឹមត្រូវ ពីព្រោះថាកាលពីល្ងាចថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១២ មានក្រុមក្មេងស្ទាវពីរក្រុមបានចូលស៊ីផឹក ត្រៃក្បែរគ្នា នៅផ្ទះលក់ស៊ុប និងគ្រឿងក្លែម យីហោ៨៨ ខាងកើតផ្លូវបំបែកភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ក្នុងអំឡុងពេលផឹកស៊ីក្រុមក្មេងទាំងពីរក្រុម បានផឹកស៊ីឌឺដងដាក់គ្នាទៅវិញទៅមក ដែលជាហេតុនាំឱ្យភាគីម្ខាងមានការគំនុំ នឹងភាគីម្ខាងទៀត។ ក្រោយពេលស៊ីផឹកចប់ភាគីក្រុមក្មេងដែលមានឈ្មោះ [redacted] មាស, ខន ក្តាម, [redacted] ថុនា, [redacted] ចិន, [redacted] ប៊ី និងឈ្មោះ [redacted] សាឯម បានជិះម៉ូតូទៅស្ទាក់ផ្លូវចាំវាយភាគីម្ខាងទៀត ដែលមានឈ្មោះ [redacted] ឌីរ៉ាក់, [redacted] លីមហួន និងឈ្មោះ [redacted] លីហាង តាមបណ្តោយផ្លូវជាតិលេខ៧ នៅម្តុំបង្គោលភ្លើង លេខ ៣៩១ ភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ បណ្តាលឱ្យជនរងគ្រោះឈ្មោះ [redacted] ឌីរ៉ាក់ ស្លាប់ នៅនឹងកន្លែងកើតហេតុរីឯឈ្មោះ [redacted] លីមហួន និងឈ្មោះ [redacted] ហ៊ាង រងរបួសធ្ងន់។ ក្រោយធ្វើសកម្មភាពហិង្សានេះរួច ជនជាប់ចោទទាំងអស់បានគេចខ្លួន។ អំពើល្មើសរបស់ជនជាប់ចោទ បានពួនស្ទាក់វាយជនរងគ្រោះឱ្យស្លាប់ភ្លាមៗនៅកន្លែងកើតហេតុ ដោយមានការពួនស្ទាក់នោះ គឺជាអំពើ ឃាតកម្មគិតទុកជាមុន ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះ ករណីនេះគប្បីសាលាឧទ្ធរណ៍ភ្នំពេញ ធ្វើការពិនិត្យពិចារណាឡើងវិញ។

៣.យល់ឃើញថា បណ្តឹងសាទុក្ខ របស់តំណាងមហាអយ្យការអមតុលាការកំពូល មានមូលហេតុសមស្របតាមមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

៤.យល់ឃើញថា តំណាងមហាអយ្យការអមតុលាការកំពូល បានកោះហៅអ្នកប្តឹងសាទុក្ខឱ្យមកចូលរួមសវនាការត្រឹមត្រូវ ប៉ុន្តែសាមីខ្លួនអវត្តមាន តែមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទមានវត្តមាន ដូច្នេះតុលាការកំពូល អាចបន្តសវនាការបាន។

៥.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៧ "ក្រ II.សវ" ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចមកនេះ ខុសគតិច្បាប់។

## ហេតុដូច្នេះ សម្រេច

១.ទទួលបណ្តឹងសាទុក្ខលេខ ១២០ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ របស់តំណាងមហាអយ្យការអមតុលាការកំពូល។

២.បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ១៧ "ក្រ II.សវ" ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញទាំងមូល។

៣.បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ១៧៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះឡើងវិញ។

-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ និងប្រកាសនាពេលសវនាការជាសាធារណៈនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២។

| | | |
|---|---|---|
| -ឯកឧត្តម | [redacted] | ប្រធាន |
| -ឯកឧត្តម | [redacted] | ចៅក្រម |
| -ឯកឧត្តម | [redacted] | ចៅក្រម |
| -ឯកឧត្តម | [redacted] | ចៅក្រម |
| -ឯកឧត្តម | [redacted] | ចៅក្រម |
| -លោក | [redacted] | ក្រឡាបញ្ជី |

បានឃើញ

ថ្ងៃ [illegible] ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០២២

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃ [illegible] ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០២២

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner